**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

*ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែ ពិសាខ ឆ្នាំ រោង ឆស័ក ព.ស ២៥៦៨*
*រាជធានីភ្នំពេញ, ថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២៤*

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ជំនួបសម្តែងការគួរសម និងជម្រាបលារបស់
# ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី
# រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ឯកឧត្តម វ៉ាង វិនធាន (Wang Wentian)
# ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន
# ប្រចាំព្រះរាជាណាចក្រកម្ពុជា

នាព្រឹកថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០២៤, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** បានអនុញ្ញាតឱ្យឯកឧត្តម **វ៉ាង វិនធាន** (Wang Wentian) **ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា** ចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងខណៈដែលឯកឧត្តមបញ្ចប់ភារកិច្ចដ៏ឧត្តុង្គឧត្តមរបស់ឯកឧត្តម នៅព្រះរាជាណាចក្រកម្ពុជា ។

ជាមួយនឹងកិច្ចសម្តែងការស្វាគមន៍យ៉ាងកក់ក្តៅ និងសោកស្តាយក្នុងឱកាសដែល**ឯកឧត្តមឯកអគ្គរដ្ឋទូត** ជម្រាបលា, បេសកកម្មការទូតដ៏ឧត្តុងឧត្តមរបស់**ឯកឧត្តមឯកអគ្គរដ្ឋទូត**នៅកម្ពុជា បានចាប់ផ្តើមតាំងពីឆ្នាំ ២០១៨ និងមកដល់ពេលនេះប្រមាណ ៦ ឆ្នាំហើយ, **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានរំលេចអំពីស្នាដៃរបស់ **ឯកឧត្តមឯកអគ្គរដ្ឋទូត** ដែលបានចូលរួមវិភាគទានជាច្រើន ក្នុងការលើកកម្រិតកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ចាប់ពីកិច្ចសហប្រតិបត្តិការភាពជាដៃគូយុទ្ធសាស្ត្រគ្រប់ជ្រុងជ្រោយទៅជាសហគមន៍វាសនារួម កម្ពុជា-ចិន និងបច្ចុប្បន្ននេះ វិវឌ្ឍន៍ជាកិច្ចសហ-ប្រតិបត្តិការត្បូងពេជ្រ និងការកសាងសហគមន៍វាសនារួម កម្ពុជា-ចិន ក្នុងយុគសម័យថ្មី ប្រកបដោយគុណភាពខ្ពស់ កម្រិតខ្ពស់និង ស្តង់ដារខ្ពស់ ។

នៅក្នុងអាណត្តិបំពេញការងារការទូតរបស់ **ឯកឧត្តមឯកអគ្គរដ្ឋទូត**, សមិទ្ធិផលធំៗជាប្រវត្តិសាស្ត្រដែលសម្រេចបានពីហិរញ្ញប្បទានសហប្រតិបត្តិការកម្ពុជា-ចិន ជាអាទិ៍ ពហុកីឡដ្ឋានជាតិមរតកតេជោដ៏ធំស្កឹមស្កៃ និងស្រស់ស្អាត, មន្ទីរពេទ្យមិត្តភាព កម្ពុជា-ចិន ព្រះកុសុមៈដ៏ទំនើប, ផ្លូវល្បឿនលឿន ភ្នំពេញ-ក្រុងព្រះសីហនុ ដែលជាផ្លូវល្បឿនលឿនទី ១ នៅកម្ពុជា, អាកាសយានដ្ឋានអន្តរជាតិសៀមរាបអង្គរ, សាលារៀន, ស្ពាន, ផ្លូវ, ប្រព័ន្ធធារាសាស្ត្រ និងកិច្ចសហប្រតិបត្តិការជាច្រើនផ្សេងទៀត ។ ទន្ទឹមនេះ, សំខាន់ជាងគេបំផុត, **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានរួមចំណែកយ៉ាងសកម្មចំពោះការផ្តល់វ៉ាក់សាំងបង្ការជំងឺកូវីដ ១៩ របស់មិត្តចិន

ដែលជាបង្អែកយុទ្ធសាស្ត្រក្នុងការជួយសង្គ្រោះជីវិតប្រជាជនកម្ពុជា និងធ្វើឱ្យកម្ពុជាអាចបង្កើតបាននូវភាពស៊ាំសហគមន៍រឹងមាំ និងបើកប្រទេស ព្រមទាំងស្តារសេដ្ឋកិច្ចឡើងវិញយ៉ាងឆាប់ និងមុនគេមួយ ក្នុងចំណោមបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកផងដែរ ។

ជាការឆ្លើយតប, **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកអនុញ្ញាតឱ្យរូបឯកឧត្តមចូលជួបសម្តែងការគួរសម និងជម្រាបលា ក្នុងឱកាសបញ្ចប់អាណត្តិបេសកកម្មការទូតរបស់ឯកឧត្តមនៅកម្ពុជា ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានបន្តថា ចិន និងកម្ពុជា គឺជាមិត្តដែកថែប ដែលនេះគឺជាកិត្តិយសណាស់សម្រាប់ឯកឧត្តមក្នុងការបំពេញតួនាទីជំរុញកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ ។ **ឯកឧត្តមឯកអគ្គរដ្ឋទូត** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** ដែលបានជួយគាំទ្រ និងផ្តល់កិច្ចសហការយ៉ាងល្អជាមួយស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្នើសុំឯ**កឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បន្តជួយគាំទ្រទៀត នៅក្នុងអាណត្តិបេសកកម្មការទូតរបស់ **ឯកឧត្តមឯកអគ្គរដ្ឋទូតថ្មី** ដែលនឹងមកបំពេញភារកិច្ចនៅព្រះរាជាណាចក្រកម្ពុជា ក្នុងពេលឆាប់ៗខាងមុខ ។

ជាទីបញ្ចប់, ជាមួយនឹងការថ្លែងកោតសរសើរចំពោះស្នាដៃរបស់ **ឯកឧត្តមឯកអគ្គរដ្ឋទូត, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី** បានសម្តែងនូវការរីករាយក្នុងការរង់ចាំស្វាគមន៍ និងបន្តកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយ **ឯកឧត្តមឯកអគ្គរដ្ឋទូតថ្មី** ព្រមទាំងសង្ឃឹមជឿជាក់ថា កម្ពុជា-ចិន នឹងទទួលបានសមិទ្ធិផលជាផ្លែផ្កាច្រើនទៀតពីកិច្ចសហប្រតិបត្តិការរវាងប្រជាជន និងប្រទេសទាំងពីរ និងបានជូនពរ ឯកឧត្តម **វ៉ាង ម៉ិនធាន** (Wang Wentian) **ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋប្រជាមានិតចិន ប្រចាំព្រះរាជាណាចក្រកម្ពុជា** មានសុខភាពល្អ និងទទួលបានជោគជ័យបន្ថែមទៀតទាំងក្នុងអាជីពការងារ និងជីវិតឯកជន ព្រមទាំងសង្ឃឹមថានឹងមានឱកាសជួបគ្នា និងបំពេញកិច្ចការងារជាមួយគ្នា ក្នុងក្របខ័ណ្ឌណាមួយនៅថ្ងៃខាងមុខ ។